**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខៈ ១២៤៣ ន.រា

ថ្ងៃ.ចន្ទ.១៤រោច.ខែ.បឋមាសាឍ.ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ.កក្កដា.ឆ្នាំ២០២៦

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដូចខាងក្រោមៈ

១-កញ្ចប់"ក": ការផ្គត់ផ្គង់សម្ភារតភ្ជាប់សម្រាប់ជួសជុលបំពង់

២-កញ្ចប់"ខ": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធក្ល័ររាវ

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្ដីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២៦ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទី ដល់ ១៦:៣០នាទី) ដល់ថ្ងៃពុធ ទី១៩ ខែសីហា ឆ្នាំ២០២៦ ត្រឹមវេលាម៉ោង ១២:០០នាទី។

កាលបរិច្ឆេទបង្ហាញទីតាំងគ្រឿងបន្លាស់ប្រព័ន្ធក្ល័ររាវ ថ្ងៃសុក្រ ទី៣១ ខែកក្កដា ឆ្នាំ២០២៦ វេលាម៉ោង ០៩:០០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវគ្រឿងបន្លាស់ប្រព័ន្ធក្ល័ររាវ គឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃព្រហស្បតិ៍ ទី២០ ខែសីហា ឆ្នាំ២០២៦ កញ្ចប់"ក" វេលាម៉ោង ១៤:០០នាទី និងកញ្ចប់"ខ" វេលាម៉ោង ១៤:១៥នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ដួ_ផល្លា**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

ប្រាក់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY

**PHNOM PENH**
**WATER SUPPLY AUTHORITY**

Nº..124 PPWSA.

Date:....13..Jul..2026......

# Invitation for Bids

Phnom Penh Water Supply Authority (PPWSA) now invites sealed bids from eligible Bidders registered in the Kingdom of Cambodia for the Supply and Delivery of:

1-Package "A": Fittings and Accessories for Pipe Repairing

2-Package "B": Spare parts of Hypochlorite system

A complete set of bidding document is available upon payment of non-refundable fee at Procurement Unit of PPWSA with the address #45, Street 106, Sangkat Srash Chork, Khan Daun Penh, Phnom Penh, working hour from Wednesday 15th July 2026 (08:00am to 16:30pm) until Wednesday 19th August 2026 at 12:00pm.

Date of location of spare parts of Hypochlorite system Friday 31st July 2026, at 9:00 AM. Failure to inspect Hypochlorite parts is the responsibility of the bidder.

Completed bids must be delivered and opened to the address above at or before **14:00pm Package "A" and 14:15pm Package "B" on Thursday 20th August 2026.** Late bids will be rejected.

Associated bidders are allowed to submit only one bid.

Interested eligible bidders may obtain further information from Procurement Unit of PPWSA at the address above or phone number 017 811 911.